# មហោស្រពជាតិ ភាពយន្តខ្លីកម្ពុជា លើកទី៣ ឆ្នាំ២០២២

# The 3rd Cambodia National Short Film Festival 2022

## ភាពយន្តខ្លីជាជំហានឆ្ពោះទៅកាន់ភាពយន្តវែង

## Short Films as a Stepping Stone to Feature Film

សាលសន្និសីទចតុម្មុខ និងរោងភាពយន្តក្នុងរាជធានីភ្នំពេញ

ថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២

16-20 December 2022

ចូលរួមទស្សនាដោយសេរី

FREE ENTRY

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សារលិខិត

## លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្នុងឱកាសប្រារព្ធមហោស្រពជាតិភាពយន្តខ្លីកម្ពុជាលើកទី៣ ឆ្នាំ២០២២

មហោស្រពជាតិភាពយន្តខ្នាតខ្លីកម្ពុជាលើកទី៣ បានវិលត្រឡប់មកវិញក្រោយពីអាក់ខានដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ដែលបានរាតត្បាតក្នុងប្រទេសយើងក្នុងរយៈពេល០២ឆ្នាំមកនេះ។ នេះជាការវិលត្រឡប់ប្រកបដោយមោទនភាព និងក្តីសង្ឃឹមសម្រាប់ផលិតករភាពយន្តវ័យក្មេងកម្ពុជា ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការ ទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការរីករាលដាលនៃជំងឺកូវីដ-១៩។

ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ ២០១៦ មហោស្រពជាតិភាពយន្តខ្នាតខ្លីកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតធនធានមនុស្សថ្មីៗ ប្រកបដោយសមត្ថភាព ទេពកោសល្យក្នុងវិស័យភាពយន្ត សម្រាប់បច្ចុប្បន្ន និងអនាគត។ យុវជនទាំងអស់បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបង្កើតស្នាដៃភាពយន្តថ្មីៗ ប្រកបដោយគំនិតច្នៃប្រឌិត ព្រមទាំងបានបង្កប់នូវអត្ថន័យខ្លឹមសារអប់រំ សីលធម៌ គុណធម៌ និងអត្តសញ្ញាណជាតិ ដែលសកម្មភាពទាំងនេះមិនត្រឹមតែបានជួយអភិវឌ្ឍន៍ឧស្សាហកម្មភាពយន្តកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សា ការពារវប្បធម៌ ប្រពៃណីទំនៀមទំលាប់របស់ជាតិយើង។

ក្នុងនាមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាអនេក និងចាត់ទុកថាការរៀបចំព្រឹត្តិការណ៍មហោស្រពជាតិភាពយន្តខ្នាតខ្លីកម្ពុជាលើកទី៣ ឆ្នាំ២០២២ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ក្រោមប្រធានបទ **"ភាពយន្តខ្នាតខ្លីជាជំហានឆ្ពោះទៅភាពយន្តខ្នាតវែង"**គឺជាការផ្តល់ឱកាសសម្រាប់យុវផលិតករវ័យក្មេងកម្ពុជាក្នុងការដកស្រង់បទពិសោធន៍ និងពង្រឹងសមត្ថភាពដើម្បីរួមចំណែកលើកកម្ពស់ឧស្សាហកម្មភាពយន្តកម្ពុជាឲ្យមានការវិវឌ្ឍន៍រីកចម្រើន។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈកម្មការរៀបចំមហោស្រព ដៃគូសហការ និងក្រុមហ៊ុននានាដែលបានចូលរួមឧបត្ថម្ភគាំទ្រដល់ដំណើរការរៀបចំមហោស្រពនាឆ្នាំនេះ។ ខ្ញុំសូមជូនពរដល់ដំណើរការរៀបចំមហោស្រពជាតិភាពយន្តខ្នាតខ្លីកម្ពុជាលើកទី៣នេះ ប្រព្រឹត្តទៅដោយជោគជ័យ ។

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

ទូរសព្ទ / ទូរសារៈ 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

KINGDOM OF CAMBODIA

Nation Religion King

Ministry of Culture and Fine Arts

**MESSAGE**

**Her Excellency Dr. Academician PHOEURNG SACKONA,**
**Minister of Culture and Fine Arts on the occasion of**
**the 3rd Cambodia National Short Film Festival 2022**

The 3rd Cambodia National Short Film Festival is back after a hiatus due to the Covid-19 crisis that has plagued our country for the past 02 years. This is a proud and hopeful return for young Cambodian filmmakers under the Royal Government of Cambodia's efforts to effectively prevent the spread of Covid-19.

Since its inception in 2016, the Cambodia National Short Film Festival has played an important role in developing new human resources with talent in the film industry for the present and the future. All young people have actively contributed to the creation of innovative films, as well as embodied the meaning of education, morality, virtue and national identity, which not only helped to develop the Cambodian film industry, but also contribute significantly to the preservation of the culture, traditions and customs of our nation.

On behalf of the Ministry of Culture and Fine Arts, I am very pleased and consider the organization of the 3rd Cambodia National Short Film Festival in 2022, which will take place from the 16th to the 20th of December, 2022 under the theme "Short Films as a Stepping Stone to Feature Films" is an opportunity for young Cambodian filmmakers to gain experience and strengthen their capacity to contribute to the growth of the Cambodian film industry.

Taking this opportunity, I would like to thank the organizing committee for the festival, partners, and companies that have supported the process of organizing this year's festival. I wish the process of organizing the 3rd Cambodia National Short Film Festival to be successful.

**Minister**

**Dr. Academician PHOEURNG SACKONA**

មហោស្រពជាតិ
ភាពយន្តខ្នាតខ្លីកម្ពុជា
លើកទី៣ ឆ្នាំ២០២២

The 3rd Cambodia National Short Film Festival 2022

## *អារម្ភកថា*

## *គណៈកម្មការរៀបចំមហោស្រពជាតិភាពយន្តខ្នាតខ្លីកម្ពុជា*

*មហោស្រពភាពយន្តខ្នាតខ្លី គឺជាព្រឹត្តិការណ៍មួយដ៏មានសារៈសំខាន់ និងចាំបាច់បំផុត នៅក្នុងបរិបទនៃយុគសម័យឌីជីថល ក្នុងការជំរុញលើកទឹកចិត្តដល់យុវជនដើម្បីបញ្ចេញនូវគំនិត ចែករំលែកផ្សព្វផ្សាយនូវព័ត៌មានដែលពួកគេមាន តាមរយៈអេក្រង់ ឬផ្ទាំងសំពត់ស ដែលនេះគឺជាជំហ៊ានដំបូងនាំពួកគេឲ្យក្លាយជាផលិតករភាពយន្ត និងជាធនធានប្រកបដោយសក្តានុពលសម្រាប់រួមចំណែកទ្រទ្រង់ និងលើកកម្ពស់ឧស្សាហកម្មភាពយន្ត។*

*ពីមួយឆ្នាំទៅមួយឆ្នាំ មហោស្រពជាតិភាពយន្តភាពយន្តខ្នាតខ្លីកម្ពុជា បានក្លាយជាចំណុចប្រសព្វយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់យុវជនកម្ពុជាពីគ្រប់មជ្ឈដ្ឋាន ជាមួយនឹងឧស្សាហកម្មភាពយន្ត ហើយក៏ជាវេទិកាអប់រំ និងបំផុសទេពកោសល្យ ការច្នៃប្រឌិត ព្រមទាំងភាពរស់រវើកដ៏សំបូរបែបនៃការផលិតភាពយន្តខ្នាតខ្លីនៅកម្ពុជាផងដែរ។*

*ក្នុងនាមគណៈកម្មការរៀបចំមហោស្រព យើងពិតជាមានសេចក្តីសប្បាយរីករាយ និងមោទកភាពយ៉ាងខ្លាំងដែលចំនួន នៃការផលិតភាពយន្តខ្នាតខ្លីនៅកម្ពុជាមានការកើនឡើងទាំងបរិមាណ និងគុណភាពគួរឲ្យកត់សម្គាល់ ដែលកត្តានេះបានសបញ្ជាក់ពីការយកចិត្តទុកដាក់ លើកទឹកចិត្ត សម្របសម្រួលរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់ឱកាសដល់យុវជនធ្វើការអភិវឌ្ឍគំនិតច្នៃប្រឌិត និងបង្កើតនូវទស្សនទានថ្មីៗ លើស្នាដៃភាពយន្តរបស់ពួកគេ ហើយសង្ឃឹមថា យុវផលិតករវ័យក្មេងទាំងអស់នឹងក្លាយជាធនធានដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍឧស្សាហកម្មភាពយន្តកម្ពុជា ប្រកបដោយនិរន្តរភាពនាថ្ងៃអនាគត។*

*សូមអរគុណ និងសូមចូលរួមរីករាយទាំងអស់គ្នាក្នុងព្រឹត្តិការណ៍មហោស្រពនាឆ្នាំនេះ ហើយគិតថា វាគឺជាមហោស្រពរបស់អ្នកទាំងអស់គ្នា។*

The 3rd Cambodia National Short Film Festival 2022

**PREFACE**

**Cambodia National Short Film Festival Organizing Committee**

The Short Film Festival is one of the most important and necessary events in this digital era to motivate young people to express their thought, share and disseminate their information on the screen as the initial step to become a filmmaker and potential human resource for contributing to the sustainability and growth of the film industry.

From year to year, the Cambodia National Short Film Festival has become an important connecting point for young Cambodians from all sector with the film industry, as well as a platform for educating and inspiring the creative and vibrant talent of short film production in Cambodia.

On behalf of the Festival Organizing Committee, we are very pleased and proud that the number of short film productions in Cambodia has increased significantly in both quantity and quality, which is a testament of the encouragement and coordination of the Ministry of Culture and Fine Arts and relevant ministries and institutions to provide opportunities for young individuals to develop creative ideas and create new films' concepts, and hope that all young maker will be important resources in contributing to the sustainable development of the future Cambodian film industry.

Thank you and please enjoy this year's festival and consider it as your own festival.




## សង្ខេបរឿង៖

សាណា ណាត់ជួបសង្សារចាស់នៅហាងអាហារ ថៃដន្យតឹមសួ ដែលជាស្វាមីឃើញ ក៏យល់ច្រលំគិតថានាងក្បត់ចិត្តគេ តែតាមពិតសាណា ណាត់ជួបសង្សារចាស់គ្រាន់តែដើម្បីសុំខ្ចីលុយ ដោះស្រាយបញ្ហាក្នុងផ្ទះតែប៉ុណ្ណោះ

## Synopsis:

Sana meet her ex in a food shop, kimsur see like this he thinks that Sana return love with her ex-boyfriend, but infect she just meet for borrow some money.





## ស្មានខុស
**Misunderstand**

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 8នាទី និង 39វិនាទី

Length : 8min 39sec



អ្នកដឹកនាំរឿង / Director

ពូ ស្រីតូច
**Pou Sreytouch**




## សង្ខេបរឿង៖

ប្ដីប្រពន្ធអ្នកមានពីរនាក់ហូបអាហារនៅរម្មណីយដ្ឋានមួយ ស្ត្រីជាប្រពន្ធកាច់ឆ្នាស់បានតថ្លៃទំនិញនំលោកយាយចាស់ម្នាក់ជាមួយនិងពាក្យសំដីមើលងាយ ។
លោកយាយខ្វះលុយអាប់ឲ្យស្ត្រីនោះ ២០០រៀល ស្ត្រីចិត្តអាក្រក់ដេញឲ្យលោកយាយដើរដូរគេយកមកឲ្យខ្លួន។ លោកយាយ រត់ទៅដូរលុយពីក្មេងរើសសំរាមពីរនាក់បងប្អូន ក្មេងប្រុសមិនមានលុយគ្រប់ដូរក៏ឲ្យលុយ ២០០រៀលជូនទៅដល់យាយឲ្យស្ត្រីម្នាក់នោះ។ ប្អូនស្រីក្មេងប្រុសម្នាក់ស្លាក់ឆ្អឹងជាខ្លាំងបងប្រុសរត់ទៅសុំទឹកពីប្ដីប្រពន្ធពីរនាក់នោះ ស្ត្រីជាប្រពន្ធហាមប្ដីមិនឲ្យទឹកទៅក្មេងប្រុសព្រោះដាក់ទានពេលហូបចុកខ្លាចគាត់លាបរកស៊ីមិនមាន ហើយស្ត្រីចិត្តអាក្រក់ដេញក្មេងប្រុសនោះនិងបានដៀលថាធំឡើងអាចជាចោរលួចចោរប្លន់។ ក្មេងស្រីឆ្លាក់ឆ្អឹងក៏បានលោកយាយលក់នំជួយយកអាសារឲ្យទឹកផឹកហើយក៏ផុតគ្រោះថ្នាក់។
ស្ត្រីចិត្តចិត្តអាក្រក់ពេលគិតលុយ បានឲ្យលុយផីបជាច្រើនទៅថៅកែហាង ហើយក៏ភ្លេចកាបូបលុយនៅទីនោះ ក្មេងប្រុសបានរើសកាបូបលុយនោះហើយក៏រត់យកទៅឲ្យស្ត្រីចិត្តអាក្រក់នោះវិញ ស្ត្រីចិត្តអាក្រក់បានដឹងកំហុសខ្លួន ហើយក៏បានជូននូវសាគុណដល់ក្មេងប្រុសនោះតែត្រូវបានក្មេងប្រុសបដិសេធមិនព្រមទទួល ហើយក៏បានប្រាប់ទៅស្ត្រីនោះថាអំពើល្អធ្វើឡើងមិនត្រូវការតបស្នងឡើយ។

# អ្នកក្រ
**Real Poor**

ប្រភេទរឿង៖ មនោសញ្ចេតនាអប់រំ

Genre : (Drama Education)

រយៈពេល៖ 17នាទី 35វិនាទី

Length : 17min 35sec



អ្នកដឹកនាំរឿង / Director

**នាង គួនណូចិត្រា**

**Neang Kounno Chitra**



## សង្ខេបរឿង៖

ស្ត្រីម្នាក់ដែលធ្វើការពេលយប់ជ្រៅនៅក្នុងហាងអ៊ុតសក់

## Synopsis:

A young woman working late at night at a beauty salon gives into her restrained interest in a young man who spends his evenings driving Phnom Penh's streets by motorbike as a delivery man








# ថ្ងៃរះក្នុងចិត្ត

# Sunrise in My Mind

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 13នាទី និង 45វិនាទី

Length : 13min 45sec



អ្នកដឹកនាំរឿង / Director

**សាន ដាណិច**

**San Danech**




## សង្ខេបរឿង៖

ដេវិឌ គឺជាមនុស្សឯកការដែរគ្មានទំនាក់ទំនងស្នេហាជាមួយនារីម្នាក់ណាឡើយ តែគាត់មានក្តីស្រមៃ នឹងពេញចិត្តនារីក្នុងក្តីស្រមៃរបស់គាត់ៗ

# ស្រទាប់ផ្កា
## The Pick

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 5នាទី និង 12វិនាទី

Length : 5min 12sec











អ្នកដឹកនាំរឿង / Director

**មឿន សូសុខហេង**

**Mourn So Sokheng**

## សង្ខេបរឿង៖

គង្គា ជាតារាបណ្ដាញសង្គមមួយរូប ដែលត្រូវរស់នៅជាប់ឃុំជាមួយប្អូនប្រុសនាងឈ្មោះគិរី និងឪពុករបស់នាងមួយរយៈដោយសារការបិទប្រទេសមួយរយៈដើម្បីទប់ស្កាត់កូវីដ១៩ ដោយសារនឹងមិនចូលចិត្តការប្រែក្លាយរបស់ឪពុកនាង ទៅជាភេទទី៣ នាងតែងតែប្រើចរិកសោះកក្រោះដាក់គេ...។

## Synopsis:

An old woman works as a road painter on a busy street in Phnom Penh City. One day while she was working on the street, she found something.






# ទឹកជ្រោះតែមួយ

## The Only One Waterfall

ប្រភេទរឿង៖ នាដកម្មបែបគ្រួសារ

Genre : (Drama)

រយៈពេល៖ 14នាទី និង 7វិនាទី

Length : 14min 7sec



អ្នកដឹកនាំរឿង / Director

**ស៊ុំ ស៊ីថែន**

**SUM Sithen**




# ជាមនុស្សស្រីខុសមែនទេ
# IS IT WRONG TO BE A WOMAN

ប្រភេទរឿង៖ អប់រំ

Genre : (Education)

រយៈពេល៖ 3នាទី និង 39វិនាទី

Length : 3min 39sec



អ្នកដឹកនាំរឿង / Director

**ភីរុណ សូរក្សា**

**Phirun Soreasa**

## សង្ខេបរឿង៖

នៅក្នុងគ្រួសារមួយមានសមាជិក៣នាក់គ្រួសារមានមុខរបរជាកសិករ ជីវភាពមានគួរសម្យ។ បងប្រុសតែងតែមិនសប្បាយចិត្តនៅពេល ប្អូនស្រីសុំទៅជួយការងារនៅកសិដ្ឋាន ព្រោះគេគិតថាមនុស្សស្រី គ្មានសមត្ថិភាពធ្វើបានដូចមនុស្សប្រុសនោះទេ។ ល្ងាចមួយគ្រួសារ ជុំគ្នាញុាំបាយដូចរាល់ដង កំពុងញុាំបាយបានបន្តិចប្អូនស្រីបានសុំ បងប្រុសទៅធ្វើការជាមួយដែល ព្រោះគាត់ចង់ជួយបងខ្លះ បងខឹងជា ខ្លាំងហើយក៏ងើបចេញទាំងម្ដាយឃាត់ក៏មិនស្ដាប់។ ប្អូនស្រី មាន អារម្មណ៍អន់ចិត្តជាខ្លាំងគិតថានិងឈប់សុំបងទៅធ្វើការជាមួយទៀត ហើយ ។ពួកគេទាំងពីរបានឈ្លោះគ្នាជាខ្លាំង ប្អូនស្រីអស់សង្ឃឹម និង ផ្គត់គំនិតបងប្រុសខ្លួនជាខ្លាំងនាងងើបចេញទាំងមិនអស់ចិត្ត។បងប្រុស ដោយឃើញប្អូនស្រីខ្លួនមិនសប្បាយចិត្តជាមួយ អ្វីដែលខ្លួនបាន បដិសេដនាងរហូតមក គាត់ក៏គិតដល់ពាក្យម្ដាយបាននិយាយពី មុននេះបន្ទិចគាត់ក៏ដឹងថាខ្លួនពិតជាបានគិតខុសលើប្អូនហើយព្រោះ តែគាត់ស្រលាញ់ប្អូនមិនចង់ឲ្យប្អូនមកពិបាកជាមួយនិងគិតថាប្អូន មិនអាចធ្វើដូងខ្លួនបាន។ ចុងបញ្ចប់គាត់ក៏ផ្លាស់ប្ដូរផ្នត់គំនិត ហើយ ងាកមកស្របតាមប្អូនស្រីរបស់គាត់វិញប្អូនស្រីរំភើបរីករាយណាស់ ដែរទទួលបានការងារដែលខ្លួនចង់ធ្វើនិងសេរីភាពនៃការ បញ្ចេញ មតិ។

## *Synopsis:*

In a family as a farmer live with three members and a comfortable life. The older brother was always unhappy when his's sister asked for help in the farm because who thought that women were not as capable as men. Once evening, the family had dinner together as usual, Sister asked her brother to work with him again because who wanted to help some of works in the farm. The oldest brother was very angry and got up and neither listen to his mother speech. Younger sister really upsets and will never talk again about it. Two of them really argued and the sister to despair with her brother's mind and got up with unsatisfied. Seeing that his sister was unhappy with what he had denies her, who thought about his mother said before of this, He realized that who thoughts wrong with sister because he loved, didn't want her to be hard with him and he think that she cannot do it like himself

Finally, he changed his mind and returned to his sister. She was excited to get the job she wanted and freedom of expression.








## សង្ខេបរឿង៖

នៅក្នុងសាច់រឿងនេះគឺចង់បង្ហាញពីសម្ថភាពរបស់តួប្រុសដែរចេះក្បាច់គុណបុរាណខ្មែរ និងឆន្ទះចិត្តស្មោះត្រង់ដោយមិនជឿ និងពាក្យញុះញង់របស់អ្នកណាម្នាក់ ដែលព្យាយាមទាញគេឲ្យដើរលើផ្លូវអាក្រក់នោះឡើយ។












# ដែកថែប

**IRON**

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama action)

រយៈពេល៖ 9នាទី និង 14វិនាទី

Length : 9min 14sec



អ្នកដឹកនាំរឿង / Director

**Tim Pek**




## សង្ខេបរឿង៖

ចិត្រា គឺជាប្រធានក្រុមហ៊ុនមួយ ដោយគាត់បានលាក់ទុកតួនាទីគាត់យ៉ាងអាថទីកំបាំង។ គាត់មានគោលបំណងមួយដែលចង់បានដៃគូរជីវិតដ៏ស្មោះត្រង់មួយដោយមិនគិតតួនាទី និងទ្រព្យសម្បត្តិ។ ដូច្នេះគាត់ក៏សម្រេចចិត្តទំលាក់ចោលនូវតួនាទី និងទ្រព្យសម្បត្តិ ដើម្បីរកស្នេហ៍ពិត។ ក្នុងរូបភាពជាបុគ្គលិកគេ ចិត្រាបានជួបរឿងរ៉ាវឧបសគ្គជាច្រើន តែទីបំផុតគាត់ក៏អាចសម្រេចក្តីស្រម៉ៃដែលទទួលបានធារ៉ាជាដៃគូរជីវិត។



# ស្នេហាកន្លះម៉ែត្រ
# Half Meter Love

ប្រភេទរឿង៖ មនោសញ្ចេតនា
Genre : (Drama)
រយៈពេល៖ 19នាទី និង 55វិនាទី
Length : 19min 55sec





អ្នកដឹកនាំរឿង / Director
**ឈិន គង្គា**
**Chhin Kongkea**






## សង្ខេបរឿង៖

វណ្ណនិងយ៉ា ជាមិត្តជិតស្និតនឹងគ្នា។ ពួកគេទាំងពីរមានចិត្តលើគ្នាទៅវិញទៅមក។ តែយ៉ាជាមនុស្សស្រីដែលមិនអាចសារភាពទៅវណ្ណមុនហើយវណ្ណជាមនុស្សប្រុសដែលអៀនច្រើន។
ថ្ងៃមួយវណ្ណ សម្រេចចិត្តសារភាពទៅយ៉ា ចំពេលដែលយ៉ាចង់លេងល្បែងជាមួយវណ្ណ។ ភាពចៃដន្យនេះធ្វើឲ្យវណ្ណឈឺចាប់យ៉ាងខ្លាំង ហើយនាងបានបាត់បង់ឱកាសក្នុងការកែតម្រូវវាអស់មួយជីវិត។

## Synopsis:

Vann and Ya, They are best friend that have known each other for long time and very close.
They both fall in love with each other, but Ya is a girl that can't confess to boy and Vann is a shy boy.
One day Vann decide to confess his feeling to Ya while Ya want to have some joke with him.
Ya joke brokes Vann heart and she lost her chance to fix it in the rest of her life.

# ខកខាន

**Missed**

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 5នាទី

Length : 5min











អ្នកដឹកនាំរឿង / Director

**គីម វ៉ាន់ហេង**

**Vannheng Kim**




## សង្ខេបរឿង៖

ឡុង ញៀនល្បែងជាន់ជន្លំ ជំពាក់បំណុលគេពេញខ្លួនក៏សម្រេចចិត្តទៅខ្ចីលុយបន្ថែមពីបងធំម្នាក់ដែលមានឥទ្ធិពលនៅប្រចាំតំបន់អនាធិបតេយ្យ។

## *Synopsis:*

Long is deeply into gambling and is in a great debt. He decided to borrow some money from a powerful gang leader in the uncontrollable arear

# សម្លាប់
# The Kill

ប្រភេទរឿង៖ អប់រំ

Genre : (Education)

រយៈពេល៖ 10នាទី និង 59វិនាទី

Length : 10min 59sec










អ្នកដឹកនាំរឿង / Director

ឆាយ ទ្រី

**Chhay Try**




## សង្ខេបរឿង៖

ការមិនស្តាប់ ឪពុកម្តាយ មានស្នេហាក្នុងវ័យសិក្សា ភ្លើតភ្លើនមិនគោរពចាស់ទុំរហូតឈានដល់ការមានកូនរវាងគ្នានឹងគ្នាដល់ពេលម្តាយស្លាប់បានដឹងកំហុស។

# កាដូរដំបូង
# THE FIRST GIFT

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 12នាទី និង 26វិនាទី

Length : 12min 26sec











អ្នកដឹកនាំរឿង / Director

**រិន រតនា**

**Rin Rothana**




# ពណ៌ស្នេហ៍

## Color of Love

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 19នាទី និង 7វិនាទី

Length : 19min 7sec



អ្នកដឹកនាំរឿង / Director

**ហុក សំណាង**

**Hok Samnang**

## សង្ខេបរឿង៖

សាច់រឿងនិយាយពីគូស្នេហ៍ខុសសាសនា១គូ ។ តួប្រុសសាសនាព្រះពុទ្ធ និងស្រីសាសនាឥស្លាមដែលពួកគេមានទំនាក់ទំនងស្នេហាជាមួយគ្នាដោយមិនឲ្យគ្រួសារទាំងសងខាងបានដឹងលឺ។ ថ្ងៃមួយពួកគេចេញមកដើរលេងកំសាន្តក៏ត្រូវបាន បងប្រុសរបស់តួស្រី និងជាមិត្តភក្តិរបស់តួប្រុសដែរនោះបានមកឃើញពីទំនាក់ទំនងពួកគេដែលបានធ្វើឲ្យគេខឹងជាខ្លាំង។ តួស្រីនាងខំអង្វរបងប្រុសឲ្យជួយលាក់ការហើយគាត់ក៏បានយល់ព្រម ចាប់ពីថ្ងៃនោះទៅគូស្នេហ៍ទាំងពីរតែងតែមានរឿងរកាំរកូស ដោយសារតួស្រីចង់ឲ្យតួប្រុសប្រញាប់ប្រាប់រឿងគ្រប់យ៉ាងទៅគ្រួសារនិងតម្រូវឲ្យចូលសាសនារបស់ខ្លួនហើយក៏ត្រូវតួប្រុសបដិសេធរួចក៏មានទំនាស់ជាមួយគ្នា រហូតទាំងពីរនាក់ដាច់ចិត្តប្រាប់រឿងគ្រប់យ៉ាងទៅកាន់គ្រួសារទាំងសងខាងឲ្យបានដឹងលឺតែ គ្រួសារទាំងសងខាងលឺហើយ មិនព្រមដាដាច់ខាតហើយក៏ចង់ឲ្យពួកគេរៀបការជាមួយអ្នកផ្សេងរៀងៗខ្លួន ដែលធ្វើឲ្យតួប្រុសលឺហើយក៏បបួលតួស្រីរត់ចេញពីផ្ទះ នឹងបានធ្វើឲ្យឳពុកម្តាយទាំងសងខាង មានវិប្បដិសារីព្រោះមិនព្រមសម្រេចតាមបំណងរបស់កូនៗ ។

## *Synopsis:*

The story is about a different-religion couple. The main characters in the story are Lisa, a beautiful Muslim girl, and Rayut, a Buddhist man, whose relationship is kept secret from their parents. One day, Rayut and Lisa went out on a date. Unfortunately, they were caught by Lisa's brother, Waheat, who is also a friend of Rayut. After he realized Rayut is dating his sister, he became furious with him. Lisa then desperately tried to implore her brother to conceal the truth from their parents and he agreed. But since then, things have become worse because Lisa wanted Rayut to reveal the truth to their family, and she insisted that Rayut convert to her religion, Islam, but he refused, and they argued until they decided to tell the whole story to both families, and they were eventually separated by their families to marry someone else. Finally, Rayut implored Lisa to elope with him and run from the house. This made their parents regret it because they had refused to fulfill their children's wishes.








## សង្ខេបរឿង៖

នារីវ័យក្មេងម្នាក់មកលំហែកាយនៅភោជនីដ្ឋានមួយកន្លែងនៅតាមបណ្តោយទន្លេ ជាមួយមិត្តភក្តិរបស់នាង។ នាងបានរំលឹកនៅអតីតកាល ហើយហាក់ដូចជាបានជួបវេទមន្តនៅតាម ដងទន្លេ និងដើមឈើនៅលើភ្នំមួយ។ ក្នុងគ្រាចម្លែកនោះ នាងបានជួបបុរសម្នាក់ហើយពួកគេក៏រំលឹកពីរឿងអតីតកាល និងភាពភ័យខ្លាចរបស់ពួកគេ រហូតដល់នាងបាត់បង់នូវស្មារតីអំពីខ្លួនឯង។

## Synopsis:

A young woman relaxes at a riverfront restaurant with a friend. She recounts her past experiences, finding enchantment in the flows of the river and the trees on the mountains nearby.Strangely, she enters a parallel riverfront with a stranger. They recount stories of fear until she finds herself realizing her existence beyond time, space or reality.




# មួយលានឆ្នាំ
## A Million Years

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 20នាទី និង 46វិនាទី

Length : 20min 46sec







អ្នកដឹកនាំរឿង / Director

**សាន ដាណិច**

**San Danech**




## សង្ខេបរឿង៖

យុទ្ធ ម្ចាស់ហាងកាហ្វេតូចមួយ អផ្សុកព្រោះសម័យកូវីដ១៩ ដ៏សោះកក្រោះល្បងស្រមៃអ្វីដែលវិជ្ជាមានថាអាចទេមនុស្សយើងស្រលាញ់គ្នាទេទោះឃើញត្រឹមម៉ាស់។

## Synopsis:

Yuth, the cafe owner during the quiet and boring of the Covid 19 time, possitively imagines if people wearing mask could still fall in love.

# ម៉ាសល្បងស្នេហ៍

**We Mask Date**

ប្រភេទរឿង៖ មនោសញ្ចេតនាបែបកំប្លែង

Genre : (Drama Comedy)

រយៈពេល៖ 11នាទី និង 7វិនាទី

Length : 19min 7sec





អ្នកដឹកនាំរឿង / Director

សេង ធី

**Seng Ty**

## សង្ខេបរឿង៖

អ្នកនិពន្ធអត្ថបទភាពយន្តម្នាក់កំពុងសរសេររឿងរបស់គាត់ ប៉ុន្តែគាត់ចាប់អារម្មណ៍ថា ក្តារចុចកុំព្យូទ័ររបស់គាត់ហាក់ដូចជាមានវេទមន្តអ្វីម្យ៉ាង។

## Synopsis:

A Screenplay writer is writing his film, but he finds out that his keyboard is magical.






# ក្តារចុច
# The KeyBoard

ប្រភេទរឿង៖ អប់រំបែបកំប្លែង

Genre : (Education Comedy)

រយះពេល៖ 6នាទី និង 46វិនាទី

Length : 6min 46sec







អ្នកដឹកនាំរឿង / Director

**វង្ស បញ្ញាវន្ត**

**Vong Panhavon**




## សង្ខេបរឿង៖

មេ(MAY) ជាក្មេងស្រីម្នាក់ដែលបានបែកបាក់ស្នេហាជាមួយមនុស្សប្រុសដែលនាងស្រឡាញ់នាងព្យាយាមគ្រប់បែបយ៉ាងដើម្បីព្យាបាលដំបៅបេះដូងរបស់នាង។ នៅចំណុចមួយដែលនាងពិបាកបំផុតទើបនាងរៀនយល់ពីមេរៀនសំខាន់ថ្មីសម្រាប់ជីវិតរបស់នាង។

## *Synopsis:*

MAY, a girl who has broken up with her love one. She has tried many things to move on. At her lowest point, she start to learn very important lesson for her life and change everything.

# ក្តីស្រឡាញ់ដែលអ្នកផ្តល់អោយ
# The Love You Gave

ប្រភេទរឿង៖ មនោសញ្ចេតនា, ជីវិត

Genre : (Drama)

រយៈពេល៖ 13នាទី និង 67វិនាទី

Length : 13min 67sec







អ្នកដឹកនាំរឿង / Director

**សាង ច័ន្ទវិសាល**
**Sang Chanvisal**

## សង្ខេបរឿង៖

នៅពេលតួសំដែងស្ថិតក្នុងស្ទូឌីយូបញ្ចូលសំឡេងដើម្បីបញ្ចូលសំឡេងភាពយន្តរបស់គេ អនុស្សាវរីយ របស់គេត្រូវបានរំលឹកឡើងសំដែងចេញនូវ ក្តីស្រលាញ់ ការផិតក្បត់ និង រឿងសោដនាដកម្ម។

## Synopsis:

When two young actors dub a film in the dubbing studio, memories of the past are ignited uncovering a shattering revelation of love, betrayal and death.










# ជីវី ស្នេហា សុខសាន្ត
## Life.Love.Bliss.

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 6នាទី និង 26វិនាទី

Length : 6min 26sec



អ្នកដឹកនាំរឿង / Director

**សុធា អ៊ីណែស**

**Sothea Ines**




## សង្ខេបរឿង៖

រ៉ូហ្សា អាយុ 32ឆ្នាំ ត្រលប់មកពីឆ្នាំ2030 ដល់ឆ្នាំ2020 ដើម្បីផ្លាស់ប្តូររឿងមួយដែលបានកើតឡើង។ នាងចង់បញ្ឈប់ខ្លួនឯងកាលពី ១០ឆ្នាំមុនដែលពីការជួបខាយអាយុ25ឆ្នាំជាអ្នកសរសេរកូដពេលថ្ងៃនិងជាអ្នកចំរៀងក្នុងបារពេលយប់។ ប្រសិនបើរ៉ូហ្សាបានជួបខាយ ពួកគេនឹងស្រលាញ់គ្នា ៣ថ្ងៃក្រោយមក ស្នេហានេះនឹងនាំឲ្យ ខាយ ស្លាប់បាត់បង់ជីវិត។

## Synopsis:

Roza, 32, comes back in time from 2030 to 2020 to change what happened – she wants to stop her younger self from meeting Kai, 25, a coder by day and a singer in a bar at night. If Roza meets Kai they will fall in love and 3 days later it will cause the death of Kai in an accident.

# ស្នេហ៍ឆ្លងវេលា
# Timeless Love

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 24នាទី និង 23វិនាទី

Length : 24min 23sec








អ្នកដឹកនាំរឿង / Director

**គឹមអាន សុផាសក្ក**

**Kimann Sophasak**

## Synopsis:

A 25 YEARS OLD CALLED SARITH WHO IS BEST FRIEND WITH RITHYCHA A SECOND HAND DRIVER OF A RICH GUY. RITHYCHA WHO HAVE A CRUSH ON SARITH SACRIFICE HIS LIFE TO COMPLETE SARITH'S WISHED. BECUASE OF THE ILL-CONSIDERATE DICISION AT THE END RITHYCHA LOST HIS LIFE BY HIS BEST FRIEND WHO HE LOVES THE MOST.




# លះបង់

## Sacrifice

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 6នាទី និង 54វិនាទី

Length : 6min 54sec












អ្នកដឹកនាំរឿង / Director

**ថោង សារិត**

**Thoung Sareth**




# មុនពេលបាត់

## Before Lose

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 6នាទី និង 30វិនាទី

Length : 6min 30sec



អ្នកដឹកនាំរឿង / Director

**កៅ ដាវីត**

**Kao David**

## សង្ខេបរឿង៖

សិទ្ធ បានទៅហាងកាហ្វេមួយដើម្បីធ្វើការ គេបានប្រទះឃើញកាបូបដៃមួយ ហើយចង់ប្រគល់វាឲ្យអ្នកលក់កាហ្វេ តែអ្នកលក់កាហ្វេមិនព្រមទទួលយកកាបូបដៃនោះពីគេទេ។ សិទ្ធិបានសម្រេចចិត្តថានឹង Post ក្នុង Facebook ថាគេរើសបានកាបូបនោះ។ មួយសន្ទុះក្រោយមក មានបុរសម្នាក់មកប្រាប់ថាជាម្ចាស់កាបូប។ ពេលសិទ្ធិនិងបុរសម្នាក់នោះកំពុងនិយាយគ្នា ស្រាប់តែមាននារីម្នាក់ទៀតចូលមកនិយាយថាជាម្ចាស់កាបូបដែរ។ ពេលនេះសិទ្ធិបានសំរេចចិត្តធ្វើតេស្តគេទាំង២នាក់ ដោយឲ្យក្រដាសម្នាក់មួយសន្លឹក ដើម្បីសរសេរពីព័ត៌មានក្នុងកាបូបនោះ។ ហើយចុងក្រោយគេបានដឹងការពិតមួយដែលភ្ញាក់ផ្អើល។

## ***Synopsis:***

Seth is going to a coffee shop for work, then he found a wallet near his table. He wants to keep it to coffee shop but they refuse. So, he decides to find the owner. Then, there are two people come and said they are the owner. Seth decide to test both of them to find the real one.









## សង្ខេបរឿង៖

មាលា រស់នៅតាមបែបសាមញ្ញ ជាមួយគ្រួសារនាងដែលមានឪពុកម្ដាយ និងបងប្រុសម្នាក់។ ខុសពីមាលា បងប្រុសចូលចិត្តជីវិតរាត្រី ទោះបីកំឡុងពេលកូវីតក៏ដោយ។ គ្រួសារនេះប្រែជាគ្រឡាប់ចាក់ ពេលដឹងថាបងប្រុសនាងឆ្លងមេរោគកូវីត...។






# ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក

**Yesterday, Today, Tomorrow**

ប្រភេទរឿង៖ នាដកម្មបែបគ្រួសារ

Genre : (Drama)

រយៈពេល៖ 15នាទី និង 35វិនាទី

Length : 15min 35sec



អ្នកដឹកនាំរឿង / Director

**សុខ សុភក្ត្រ**

**Sok Sopheak**




## សង្ខេបរឿង៖

ស្ត្រីចំណាស់ម្នាក់ប្រកបរអាជីពជាអ្នកលាបថ្នាំពណ៌លើគំនូសចែករបាំងផ្លូវ នៅដងវិថីដ៏មមាញឹកមួយក្នុងទីក្រុងភ្នំពេញ។ ថ្ងៃមួយពេលកំពុងបំពេញការងារ គាត់បានជួបរឿងមួយដែល នឹកស្មានមិនដល់។

## *Synopsis:*

An old woman works as a road painter on a busy street in Phnom Penh City. One day while she was working on the street, she found something.

# អ្នកលាបថ្នាំ
# A Road Painter

ប្រភេទរឿង៖ ជីវិត និងការអប់រំ

Genre : (Education)

រយៈពេល៖ 5នាទី និង 10វិនាទី

Length : 5min 10sec



អ្នកដឹកនាំរឿង / Director

**ស៊ិន ចន្ថា**
**SIN Chantha**










## សង្ខេបរឿង៖

ថ្ងៃចុងសប្ដាហ៍មានក្មេងៗ បីនាក់ជាមិត្តភក្តិនិងគ្នានាំគ្នាជិះកង់កំសាន្តតាមស្រុកព្រៃ ពួកគេជិះយ៉ាងសប្បាយៗតែរអកុសលមិត្តម្នាក់បានគ្រឡាចថ្មដួលរបួសជើរនៅកណ្ដាលព្រៃតែឯង សំណាងហើយមានពូរកសិករម្នាកជិះកាត់បានជួយគាត់ៗ រំលងបានមួយរយៈគ្រោះទឹកជំនន់ក៏កើតមានជាបន្តបន្ទាបនៅតាមបណ្ដាស្រុកនៅកម្ពុជាៗពួកគេបានឃើញសារព័ត៌មានផ្សាយពីភូមិដែលពួកគេបានធ្លាប់ជិះកង់ទៅលេង ពួកគេមិនបង្អង់យូរក៏ហៅគ្នាយកជំនួយម្នាក់បន្តិចៗទៅជួយលោកពូរដែលធ្លាប់បានជួយពួកគេនិងប្រជាជនផ្សេងៗតាមដែលពួកគេជួយទៅបានៗ ធ្វើល្អ ផលល្អនិងសងអ្នកវិញនៅពេលមួយ ។

## Synopsis:

Once the weekends, there are three persons were friends and rode the bicycles through the countryside, they did really happy. Unfortunately, a friend got stone floor causes falls and got leg injuries in the middle of the field alone, luckily has an uncle's farmer who passed by and helped her.

After a while, the Floods also occur continuously in various districts in Cambodia. They saw the news that is broadcasts from the village where they used to ride their bikes, they did not hesitate to ask for donations from one by one to the uncle who used to help them and other people as they could do.

Good deeds, good results will pay you back in no time.



## ទឹកចិត្ត
## Kindness

ប្រភេទរឿង៖ អប់រំ

Genre : (Educationគ)

រយះពេល៖ 3នាទី និង 5វិនាទី

Length : 3min 5sec



អ្នកដឹកនាំរឿង / Director

**ភិរុណ សូរស្សា**
**Phirun Soreasa**




## សង្ខេបរឿង៖

វិបុល និងប្អូនប្រុសជីដូនមួយឈ្មោះគា លក់គុយទាវតាមម៉ូតូរ៉ឺម៉ក រាល់យប់នៅតាមផ្លូវនានាក្នុងក្រុងភ្នំពេញ។ ពួកគេតែងតែត្រូវពួកអ្នកលេង និងចោរគំរាមកំហែង។ បងប្អូនទាំងពីរស្វែងរកសុខសុវត្ថិភាព សម្រាប់អនាគតពួកគេខណៈពេលដែលទីក្រុងរីកចម្រើនទៅៗ ជុំវិញខ្លួនពួកគេ។

# សំឡេងរាត្រី
## Sound of The Night

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 19នាទី និង 47វិនាទី

Length : 19min 47sec





អ្នកដឹកនាំរឿង / Director

សុខ ចាន់រ៉ាដូ

**Sok Chanrado**




## សង្ខេបរឿង៖

ប៊ិចមួយដើម ត្រូវបានសិស្សម្នាក់ទិញយកមកសរសេរ និងបាន ជួយនាងប្រលងបាក់ឌុបជាប់ ប៉ុន្តែប៊ិចនោះត្រូវបានគេបំភ្លេច និង បោះបង់ចោល

## *Synopsis:*

A pen was bought by a young student and it helped her to passed graduation exam. However, the pen has been forgotten and thrown away.

# ប៊ិចសរសេរ

## The Pen

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 5នាទី និង 55វិនាទី

Length : 5min 55sec











អ្នកដឹកនាំរឿង / Director

**សុង ហេមគីរី**

**SONG HEMKIRY**




# កូនអាក្រក់ណាស់

## Too Bad To Be

ប្រភេទរឿង៖ មនោសញ្ចេតនាបែបអប់រំ

Genre : (Drama and Education)

រយៈពេល៖ 26នាទី

Length : 26min



អ្នកដឹកនាំរឿង / Director

**ទេព គឹមឡេង**

**Tep Kimleng**

## សង្ខេបរឿង៖

ស្ត្រីជាម្តាយ រស់នៅក្នុងជីវិតមេម៉ាយត្រូវបានលែងលះគ្នា និងត្រូវចិញ្ចឹមកូន៣នាក់ ក្នុងនោះមានកូនស្រី២ ប្រុស១នាក់។ កាលមករស់នៅទីក្រុងភ្នំពេញដំបូង៤នាក់ម្តាយកូន ស្នាក់នៅជាមួយគេ ស៊ីឈ្នួលគេដើម្បីចិញ្ចឹមកូន និងឲ្យកូនបានរៀនសូត្រដូចកូនគេ។ លុះកូន ទាំង៣ធំឡើង មានគ្រួសាររៀងៗខ្លួន ដោយផ្ទះតូចក៏ចង្អៀតកូនៗក៏បានរស់បែកឆ្ងាយពីម្តាយរៀងៗខ្លួន។ពេលម្តាយឈឺបានខលទៅកាន់កូនស្រីច្បងដែលនៅឆ្ងាយ ហើយក៏បានឲ្យម្តាយខលទៅកូនទី៣ដែលជាកូនពៅដោយពាក្យគម្រុះគម្រើយមិនខ្វល់ពីម្តាយ។ កូនពៅទទួលដំណឹងអំពីម្តាយឈឺ តែរវល់ការងារច្រៀងតាម ខេត្តទើបមិនខ្វលពីម្តាយដូចគ្នាព្រោះរអាងបងបង។ ម្តាយក៏សម្រេចចិត្តខលទៅកូនប្រុសចុងក្រោយគេដោយសារតែគាត់មិនសូវបានថែទាំកូនទី២ទេតាំងពីក្មេងមក។កូនប្រុសទី២ក៏ខិតខំស្វិតស្វែងទោះខ្លួនលំបាកដើម្បីជួយម្តាយបានទៅមន្ទីរពេទ្យ។ពេលម្តាយរៀងធូរស្រាលទើបបងស្រីនិងប្អូនស្រីពៅមកមើលម្តាយ។ទាំងដែរពួកគេនិងម្តាយមិនដឹងពីប្អូនប្រុសទី២មានជំងឺយ៉ាងរ៉ាំរ៉ៃតាំងក្មេងមកទេ។ទាំងអស់គ្នាក៏មានភាពសោកស្តាយជាខ្លាំងដោយបាត់បង់កូននិងប្អូនប្រុសដ៏ល្អ។

## *Synopsis:*

Her life as a widow included raising three children, including two daughters and one son. When the three children grew up, they had their own families because the house was too small, and they lived far away from their mothers. Her mother, who was ill, called her eldest daughter, who was far away, and requested that she contact her third daughter instead. When the youngest daughter received the news that her mother was sick but busy working in the provinces, she did not worry and thought that her eldest sister and older brother could take care of her. The mother decided to call her second son for the last time. When the second son heard, he was very worried and scared. He did not think about anything. He tried to find out, and no matter how difficult it was, he hurried to take his mother to the hospital as soon as possible. They and their mother did not know that the second brother had had a severe physical illness since he was a child. When the mother is ill, she knows that only her second son will not abandon her. But every time the mother calls, she asks where the second son is and how he is. The son always said he was fine both in the hospital and the emergency room. Finally, everyone is very sad to lose this wonderful and poor son, beloved, and grateful brother!

The moral of the story:

No one wants to lose a loved one! So love and take care of each other! Do not miss the time to regret it later!




## សង្ខេបរឿង៖

នារីម្នាក់មានគ្រួសារដ៏កក់ក្តៅ និងមានការងារជាអ្នកគ្រប់គ្រងក្នុងក្រុមហ៊ុនទេសចរណ៍មួយកន្លែង។ នាងបានរងគ្រោះជាមួយវិបត្តិកូវីត១៩ ដែលធ្វើឲ្យនាង ជួបវិបត្តិហិរញ្ញវត្ថុ ។ ចាប់ពីពេលនោះមកនាងរស់ដោយពឹងលើចំណូលរបស់ប្តី ព្រោះក្រោយអស់ការងារធ្វើនាងមិនអាចរកការងារថ្មីបាននោះទេ ដោយសារនាងមានបទពិសោធន៍តែផ្នែកខាងទេសចរណ៍ប៉ុណ្ណោះ។ ក្រោយមកជំនួញប្តីរបស់នាងត្រូវបានទឹកជំនន់បំផ្លាញខ្ទិចដែលធ្វើឲ្យពួកគេអស់សង្ឃឹមជាខ្លាំង ព្រោះនៅជាប់បំណុលធនាគារ ដែលតម្រូវឲ្យលក់ទ្រព្យសម្បត្តិជាច្រើននៅសល់តែផ្ទះដែលពួកគេកំពុងរស់នៅ ។ ដោយទាល់ច្រកពេកពួកគេក៏សម្រេចចិត្តសុំដីមុខផ្ទះម្តាយដើម្បីបើកតូបលក់កាហ្វេតូចមួយហើយម្តាយក៏យល់ព្រមដោយសេចក្តីអាណិត។ លក់មិនបានប៉ុន្មានផងជម្ងឺកូវីត បានឆ្លងរាលដាលកាន់តែខ្លាំងធ្វើឲ្យមានការប្រកាសអាសន្ន និងបិទខ្ទប់ក្នុងតំបន់ដែល ពួកគេរស់នៅ ចំណែកប្តីរបស់នាងក៏បានឆ្លងកូវីតទៀតផងដែលធ្វើឲ្យនាងមានការប៉ះទង្គិចផ្លូវចិត្ត គិតអវិជ្ជមាន ពីរមួយថ្ងៃទៅមួយថ្ងៃ រហូតចង់គិតខ្លី ក្រោយពេលនាងបានដឹងថា ខ្លួនកំពុងតែផ្ទុកមេរោគកូវីតដែរ។ តែក្រោយពីឃើញកូនប្រុសសម្លឹងមកកាន់ខ្លួននិងស្រែកប្រាប់ថាឃ្លាន នាងក៏ភ្ញាក់រឮកហើយក៏ខំពង្រឹងផ្លូវចិត្តរបស់ខ្លួនឲ្យល្អឡើងវិញរហូតនាងអាចស្រោចស្រង់ជីវភាពគ្រួសារមកល្អដូចដើម ។

## Synopsis:

A woman has a warm family and she is a manager of a tour company. She faced the covid crisis and struggling with financial crisis. From that time she depends on her husband because she has no job and she could not find any other jobs, because she only good at tourism field. But everything is not going as she expected, because the flood has been damaged all her husband's machines. They are really hopeless because they still have debt with the bank, so they have to sell alot of properties and they have only one house left. They have no choice, then they asked their mom to have a small coffee shop infront of her home and she agreed. This business just started, but covid is getting worse and it was lockdown in the city. Her husband tested positive, It affected her mind from day to day until she thinks negatively and has thought about doing suicide. After her son called her and told her that he is hungry, she realized and tried to strengthen her mind to get better.





# ពន្លឺជីវិត
## Light of Life

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 12នាទី និង 58វិនាទី

Length : 12min 58sec



អ្នកដឹកនាំរឿង / Director

**សេង គីមហាន**

**Seng Kimhan**




## សង្ខេបរឿង៖

ចាក ជាមនុស្សស្រីម្នាក់ដែរធ្លាប់តែស្ងប់ស្ងត់ រហូតរងសម្ពាធផ្លូវចិត្តពីសំណាក់ដៃគូស្នេហ៍របស់គាត់ដែលធ្វើបាបលើរូបនាង ហើយឲ្យនាងប្រែប្រួលទៅជាមនុស្សម្នាក់ផ្សេងទៀត។

## Synopsis:

CHAK used to be a calm person but she was under emotional pressure from her partner, which made her change into another person.

# ចាក់

## Chak

ប្រភេទរឿង៖ ជីវិត និងការអប់រំ

Genre : (Drama and Education)

រយៈពេល៖ 20នាទី និង 46វិនាទី

Length : 20min 46sec





អ្នកដឹកនាំរឿង / Director

**អ៊ុន រ៉ាដែន**

**Raden UN**

## សង្ខេបរឿង៖

ស្រ្តីជនជាតិដើមម្នាក់ និងបងប្រុសនាង ចំណាយពេលមួយថ្ងៃចុងក្រោយជាមួយគ្នាមុនពេលចាកចេញរៀងខ្លួនទៅភ្នំពេញពីភូមិរបស់ពួកគេដែលស្ថិតនៅខាងភាគឦសាននៃប្រទេសកម្ពុជា។ខណៈពេលដែលបងប្រុសនាងមានការត្រេកត្រអាលចំពោះការផ្លាស់ប្តូរជីវិតទៅនៅទីក្រុងនាងមានអារម្មណ៍ចង់ត្រលប់មកភូមិរបស់នាងដែលបានបាត់បង់ទៅតាមការអភិវឌ្ឍន៍វារីអគ្គីសនីប៉ុន្មានឆ្នាំមុននេះ។

## Synopsis:

A young indigenous Bunong woman and her older brother spend one last day in their rural village in northeastern Cambodia, before an impending move to the capital city in search of a more prosperous life. While her brother is excited for the move, she senses a quiet desire to return to their long-gone village that was lost to the development of a nearby hydroelectric dam a few years earlier.




# ឆ្ងាយដាច់អាល័យ

## Further and Further Away

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 23នាទី និង 39វិនាទី

Length : 23min 39sec







អ្នកដឹកនាំរឿង / Director

**លី ប៉ូឡែន**

**Ly Polen**




## សង្ខេបរឿង៖

ស្ត្រីពីរនាក់មានជីវប្រវត្តិខុសគ្នាបានមកជួបនៅរមណីយដ្ឋានមួយក្បែរឧទ្យានសមុទ្រហើយក៏ប្រទះដោយមិនដឹងខ្លួនរអំពីចំណងជាប់គ្នារបស់អ្នកទាំងពីនោះៗដែលចំណងនេះធ្វើឲ្យពួកគេគេចផុតនៅភាពការពិតចំពោះមុខៗ

## *Synopsis:*

Two women from different backgrounds encounter one another at an oceanfront resort and discover a hidden bond that ties them together, allowing them to escape from their realities.

# សុបិន្តកាលីហ្វ័រញ៉ា
## California Dreaming

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 16នាទី និង 13វិនាទី

Length : 16min 13sec







អ្នកដឹកនាំរឿង / Director

**មាស ស្រីលីន**
**Meas Sreylin**

## សង្ខេបរឿង៖

យប់មួយក្នុងទីក្រុងភ្នំពេញ អ្នករាំចង្វាក់ហ៊ីបហប់បីនាក់ជិះម៉ូតូតាមផ្លូវហើយក៏ឈប់នៅលើផ្លូវស្ងាត់មួយកន្លែង។ នីក ដើរចេញមកម្នាក់ឯង មករកទូរស័ព្ទ ដែលបានលឺគេថាត្រូវបានជ្រុះបាត់នៅម្ដុំនោះ។ ពិសិដ្ឋ និង ធី ពិភាក្សាគ្នាអំពីក្ដីសង្ឃឹម និងមន្ទិលរបស់ពួកគេ។ ពិសិដ្ឋក៏បង្ហាញក្បាច់រាំ Michael Jackson ដែលខ្លួនបានរៀន។ បន្ទាប់មកពួកគេក៏បានជួបលក្ខិណាដែលជានារីវ័យក្មេងម្នាក់លក់ម្ហូបតាមផ្លូវ។ រទេះម្ហូបរបស់នាង ពោរពេញទៅដោយពន្លឺភ្លើងពណ៌។

## *Synopsis:*

Phnom Penh at night. Three young hip-hop dancers drive a single motorbike and stop on a muddy deserted road. Nick leaves the others to look for an iPhone he heard was lost in the area. Piseth and Thy discuss their hopes and doubts, and Piseth shows his best Michael Jackson moves. They meet Leakhena, a young female street vendor whose cart is full of colors




# ដីថ្មី ផ្លូវខូច
# New Land Broken Road

ប្រភេទរឿង៖ ជីវិត និងការអប់រំ

Genre : (Drama and Education)

រយៈពេល៖ 5នាទី និង 10វិនាទី

Length : 5min 10sec







អ្នកដឹកនាំរឿង / Director

**នាង កាវិច**

**Kavich Neang**




## សង្ខេបរឿង៖

នៅពេលអាចម៍ផ្កាយមកបុកឋានព្រះចន្ទរំឡងពេលចន្ទគ្រាសនោះ សាយ ឃុន និងដេត ទទួលបានឱកាសធ្វើដំណើរឆ្លងទៅអតីតកាល ដើម្បីមើលពីអ្វីដែលពួកគេមិនធ្លាប់បានដឹង ប៉ុន្តែអ្វីដែលសំខាន់គឺ ពួកគេមិនអាចផ្លាស់ប្តូរអ្វីទាំងអស់។

## *Synopsis:*

When news of a meteorite hitting the moon and causing a lunar eclipse arrives, the three students, SAII, KHUN, and DETH, travel back in time to see something they never knew existed, but the important thing is that they can see everything but cannot change anything.

# ពីក្រោយការពិត
# THE TRUTH UNTOLD

ប្រភេទរឿង៖ វិទ្យាសាស្ត្រប្រឌិត

Genre : (Fiction Science)

រយៈពេល៖ 28នាទី និង 12វិនាទី

Length : 28min 12sec















អ្នកដឹកនាំរឿង / Director

**មួង ឫទ្ធី**

**Moung Rithy**




## សង្ខេបរឿង៖

នារីម្នាក់កំពុងសួរចម្លើយសង្សាររបស់នាងថា តើបានធ្វើកំហុសអ្វីមួយឬក៏អត់?

## *Synopsis:*

A girl is asking her boyfriend if he did create a big mistake or not?

# អ្នកស៊ើបអង្កេតស្រី
# Female Detective

ប្រភេទរឿង៖ អប់រំបែបកំប្លែង

Genre : (Education, Comedy)

រយៈពេល៖ 3នាទី និង 18វិនាទី

Length : 3min 18sec







អ្នកដឹកនាំរឿង / Director

**វង្ស បញ្ញាវន្ត**

**Vong Panhavon**




## សង្ខេបរឿង៖

ក្នុងជីវិតមនុស្សតែងមានការច្រណែននឹងអ្នកដទៃចុះបើមានមនុស្សដែលមិនមានការច្រណែនតែបែរជាភ័យខ្លាចនឹងការច្រណែនរបស់អ្នកដទៃវិញ?តើការច្រណែនទាំងអស់នោះជាអ្វីដែលយើងគួរយកមកគិត?ក៏យើងអាចបំភ្លេចការគិតទាំងនោះបាន...ស្នេហានិងការច្រណែនជាមធ្យោបាយរបស់មនុស្សដើម្បីគេចពីពិភព របស់ខ្លួន ប៉ុន្តែតើការស្អប់ក៏ជាផ្នែកមួយនៃការគេចចេញដែរឬទេ?យើងនឹងមិនដឹងថាមានអ្វីកើតឡើង នៅក្នុងអ្នកណាម្នាក់ឡើយ ប្រសិនបើគេមិនព្រមចែករំលែក ឬ ខ្លាចគេឃ្លាតចេញ។

## Synopsis:

Love and Jealousy are both way of people to escape their world but does hate is also part of escaping ? we will never know what happen inside someone if they are not willing to share or if they are afraid of being

# នារីក្នុងក្តីស្រមៃ
# DREAM GIRL

ប្រភេទរឿង៖ មនោសញ្ចេតនា

Genre : (Drama)

រយៈពេល៖ 7នាទី

Length : 7min







អ្នកដឹកនាំរឿង / Director

**ទី ទេពនិមល**

**Ty Tipnimol**

## សង្ខេបរឿង៖

អានដា ជាមនុស្សចម្លែកម្នាក់ខុសពីអ្នកដទៃ អ្វីដែររឹតតែចម្លែកទៅទៀតនោះគឺក្ដីស្រលាញ់របស់នាងមិនត្រូវការជីវិតឡើយអ្វីដែរនាងចង់បានគ្មាននរណាអាចបានពុក្រៅពីគាត់ឡើយ ។

## Synopsis:

Anda is an erratic, unlike anyone else, what is even more strange is that her love doesn't need alive.








## អានដា
## ANDA

ប្រភេទរឿង៖ ឧក្រិដ្ឋកម្មមនោសញ្ចេតនា

Genre : (Crime Drama)

រយៈពេល៖ 7នាទី និង 23វិនាទី

Length : 7min 23sec



អ្នកដឹកនាំរឿង / Director

**រស់ ស្រីនិត**

**Ros Sreynith**





## Synopsis:

In the town of Battambang: Birthplace of Cambodian circus, bombastic virus and news bedevil an innocent young circus boy, Theara. His best friends unite and play a circus for him.

# សៀកតូច
# A Little Circus

ប្រភេទរឿង៖ ជីវិត និងការអប់រំ

Genre : (Drama and Education)

រយៈពេល៖ 26នាទី និង 45វិនាទី

Length : 26min 45sec









អ្នកដឹកនាំរឿង / Director

**Yoshiro Osaka**

# ក្រុមភាពយន្តឯកសារខ្លី សម្រាប់ចាក់បញ្ចាំង (មិនប្រកួតប្រជែង)

មហោស្រពជាតិភាពយន្តខ្លីកម្ពុជាលើកទី៣ មានកិត្តិយស សូមនាំមកជូននូវស្នាដៃ ភាពយន្តឯកសារខ្លីៗ ដែលបង្ហាញពីជីវិត ប្រពៃណី វប្បធម៌ ក៏ដូចជាបរិស្ថានតាមដងទន្លេមេគង្គ នៅកម្ពុជា។ ស្នាដៃភាពយន្តឯកសារទាំងនេះគឺជាស្នាដៃរបស់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលជំនាញផលិតភាពយន្តឯកសារ ដែលរៀបចំដោយ មជ្ឈមណ្ឌលធនធានសោតទស្សន៍ បុប្ផាណា។

# Short Documentary Films (Showcase Out-of-Competition)

*Cambodia National Short Film Festival proudly presents short documentary films as a special showcase produced by young Cambodian filmmakers. The films explore Cambodian realities, lives, traditions, culture, and natural resources along the Mekong river, and were the outcome of a documentary production training project hosted by Bophana Audiovisual Resource Center.*

# ភាពយន្តឯកសារខ្លីចូលរួម ចាក់បញ្ចាំងជាសាធារណៈ




















មហោស្រពជាតិ
ភាពយន្តខ្លីកម្ពុជា
លើកទី៣ ឆ្នាំ២០២២
The 3rd Cambodia National Short Film Festival 2022

# ភាពយន្តឯកសារខ្លីចូលរួម ចាក់បញ្ចាំងជាសាធារណៈ


















# ភាពយន្តឯកសារខ្លីចូលរួម
# ចាក់បញ្ចាំងជាសាធារណៈ




















មហោស្រពជាតិ
ភាពយន្តខ្លីកម្ពុជា
លើកទី៣ ឆ្នាំ២០២២
The 3rd Cambodia National Short Film Festival 2022

# ភាពយន្តឯកសារខ្លីចូលរួម ចាក់បញ្ចាំងជាសាធារណៈ


















# ភាពយន្តឯកសារខ្លីចូលរួម ចាក់បញ្ចាំងជាសាធារណៈ




















# ភាពយន្តឯកសារខ្លីចូលរួម ចាក់បញ្ចាំងជាសាធារណៈ













មហោស្រពជាតិ
ភាពយន្តខ្លីកម្ពុជា
លើកទី៣ ឆ្នាំ២០២២
The 3rd Cambodia National Short Film Festival 2022

មហោស្រពជាតិ ភាពយន្តខ្លីកម្ពុជា លើកទី៣ ឆ្នាំ២០២២

The 3rd Cambodia National Short Film Festival 2022

# កម្មវិធីបញ្ចាំង

# Screening Schedule

## ភាពយន្តខ្លីប្រកួតប្រជែង (Short Film Competition)

| SLOT | Title | Duration |
|---|---|---|
| SLOT 1 (106mn) | ស្ពានខុស | 8:39mn |
| | អ្នកក្រ (Real Poor) | 17:35mn |
| | ព្រះអាទិត្យរះក្នុងចិត្ត (Sunrise in my mind) | 13:45mn |
| | ស្រទាប់ផ្កា (The Pick) | 5:12mn |
| | ទឹកជ្រោះតែមួយ (The Only One Waterfall) | 14:07mn |
| | ជាមនុស្សស្រីខុសមែនទេ (Is it Wrong to be a Woman) | 3:18mn |
| | IRON | 9:14mn |
| | ស្នេហ៍កន្លះម៉ែត្រ | 19:55mn |
| | ខកខាន (Missed) | 5:00mn |
| | The Kill | 10:59mn |
| SLOT 2 (114mn) | កាដូដំបូង (The First Gift) | 12:26mn |
| | ពណ៌ស្នេហ៍ (Color of Love) | 19:07mn |
| | មួយលានឆ្នាំ (A Million Years) | 20:46mn |
| | We Mask Date | 11:07mn |
| | ក្ដារចុច (The Keyboard) | 6:46mn |
| | ក្ដីស្រឡាញ់ដែលអ្នកផ្ដល់ឲ្យ (The Love You Gave) | 13:57mn |
| | ជីវិត ស្នេហា សុខសាន្ត (Life Love Bliss) | 6:26mn |
| | ស្នេហ៍ឆ្លងវេលា (Timeless Love) | 24:23mn |
| SLOT 3 (116mn) | សៀកតូច (Little Circus) Note: Out of Competition | 26.56mn |
| | មុនពេលបាត់ | 6:30mn |
| | ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក (Yesterday Today | 15:35mn |
| | អ្នកលាបថ្នាំ (A Road Painter) | 5:10mn |
| | ទឹកចិត្ត | 3:50mn |
| | សំឡេងរាត្រី (Sound of the Night) | 19:47mn |
| | ប៊ិចសរសេរ (The Pen) | 5:55mn |
| | កូនអាក្រក់ណាស់ | 20:30mn |
| | ពន្លឺជីវិត (Light of Life) | 12:58mn |
| SLOT 4 (113mn) | ចាក (Chak) | 5:30mn |
| | ឆ្ងាយដាច់អាល័យ (Further and Further Away) | 23:39mn |
| | សុបិនកាលីហ្វ័រញ៉ា (California Dream) | 16:13mn |
| | ដីថ្មី ផ្លូវខូច (New Land Broken Road) | 15:20mn |
| | ពីក្រោយការពិត (The Truth Untold) | 28:12mn |
| | អ្នកស៊ើបអង្កេតស្រី (Female Detective) | 3:18mn |
| | នារីក្នុងក្ដីស្រមៃ (Dream Girl) | 7:00mn |
| | អានដា (Anda) | 7:23mn |
| | លះបង់ (Sacrifice) | 6:54mn |

| SLOT | Date | Major Cineplex | | Legend Cinema | | Prime Cineplex | | Bophana Center | French Institute |
|---|---|---|---|---|---|---|---|---|---|
| | | Aeon 1 | Aeon 2 | Olympia | Eden | Chomchaov | Samai | | |
| SLOT 1 | 16th Dec | 12:30pm | | | | | | 2:30pm | 10:00am |
| | 17th Dec | | | | 5:30pm | | 2:30pm | | |
| | 18th Dec | | | 5:30pm | | | | | |
| | 19th Dec | | 2:30pm | | | | | 10:00am | |
| | 20th Dec | ពិធីបិទមហោស្រព និងប្រកាសជ័យលាភី ( សាលសន្និសីទចតុមុខ ) Closing and Award Ceremony at Chaktomuk Conference Hall | | | | | | | |
| SLOT 2 | 16th Dec | | | 5:30pm | | 12:30pm | | | 12:30pm |
| | 17th Dec | | 2:30pm | | | | | 5:30pm | |
| | 18th Dec | 12:30pm | | | | | | | |
| | 19th Dec | | | | | | 10:00am | 12:30pm | 2:30pm |
| | 20th Dec | ពិធីបិទមហោស្រព និងប្រកាសជ័យលាភី ( សាលសន្និសីទចតុមុខ ) Closing and Award Ceremony at Chaktomuk Conference Hall | | | | | | | |
| SLOT 3 | 16th Dec | | 2:30pm | | | | | | 5:30pm |
| | 17th Dec | 12:30pm | | | | | | 2:30pm | |
| | 18th Dec | | | | | 12:30am | | 2:30pm | |
| | 19th Dec | | | 12:30pm | 2:30pm | | | | 12:30pm |
| | 20th Dec | ពិធីបិទមហោស្រព និងប្រកាសជ័យលាភី ( សាលសន្និសីទចតុមុខ ) Closing and Award Ceremony at Chaktomuk Conference Hall | | | | | | | |
| SLOT 4 | 16th Dec | | | | | | 10:00am | 12:30pm | 2:30pm |
| | 17th Dec | | | 12:30pm | | | | | |
| | 18th Dec | | 2:30pm | | | | | 5:30pm | |
| | 19th Dec | 5:30pm | | | | 12:30pm | | | 10:00am |
| | 20th Dec | ពិធីបិទមហោស្រព និងប្រកាសជ័យលាភី ( សាលសន្និសីទចតុមុខ ) Closing and Award Ceremony at Chaktomuk Conference Hall | | | | | | | |

## ភាពយន្តឯកសារ (Short Documentary Film )

| SLOT | Title | Duration |
|---|---|---|
| SLOT 1 (91mn) | ខ្ញុំគឺកម្ពុជា (Iam Cambodia) | 4:30mn |
| | ជានឪ ផ្លូវកូន (Following Dad's Path) | 19:20mn |
| | ជម្រកបៃតង (Green Home) | 24:40mn |
| | ភោគទ្រព្យមេគង្គ (Treasure of the Mekong) | 12:16mn |
| | ស្រមោលអ្នកណា (Whose Shadow) | 19:55mn |
| | គ្មានជម្រើស (No Choice) | 11:10mn |
| SLOT 2 (107mn) | ពេជ្រក្នុងទន្លេ (Dimond in the River) | 13:12mn |
| | លើទូក លើទឹក (On the Boat On the River) | 10:46mn |
| | ចាកកំពង់ | 11:18mn |
| | ផ្ទះអត់សសរ (Pillarless House) | 17:39mn |
| | ជំហានបន្ទាប់(Next Steps) | 12:07mn |
| | សន្សំ (Save) | 12:08mn |
| | ចំណែក (Apart) | 15:39mn |
| | ប៉ា ដក មើក (SANOUNG) | 14:44mn |
| SLOT 3 (97mn) | ទុកភ្លេង (My Daily Food) | 14:58mn |
| | ក្រោយឆ្នាំ ១៩៩៣ (After 1993) | 12:08mn |
| | បឹងឈូក (The Lotus Lake) | 14:50mn |
| | ដានស្រអាប់ (Dull Trail) | 11:38mn |
| | មរតក (Memories) | 14:28mn |
| | ចម្លើយ (Answers) | 14:07mn |
| | ភ្លេងខ្ញុំ (Tro Khlok Maker) | 14:14mn |
| SLOT 4 (110mn) | ស្ងូត (Under the Darkness) | 19:17mn |
| | គោមខ្មែរថៃរកេរ្តិ៍ (Khmer Lantern) | 9:01mn |
| | ឆ្លងស្ពាន (Crossing the Bridge) | 20:01mn |
| | តំណក់ទឹក (A Tasty Drop) | 24:25mn |
| | កាណ (Traps) | 12:56mn |
| | ឧស្សាហ៍សមុទ្រ (Sea Within a Sea) | 24:13mn |
| SLOT 5 (108mn) | បេះដូងរ៉ាមសា (Ramsa Heart) | 18:32mn |
| | ជម្រកខ្ញុំ (My Home) | 28:42mn |
| | គ្រាន់ជាសុបិន (My Wish) | 18:12mn |
| | អង្គ្រឹះ (Angkreus) | 10:11mn |
| | រសាត់ (On the Move) | 12:05mn |
| | Pegeon and I | 8:23mn |
| | រ៉ាង៉ត (Rarngot) | 12:48mn |

| SLOT | Date | Major Cineplex | | Legend Cinema | | Prime Cineplex | | Bophana Center | French Institute |
|---|---|---|---|---|---|---|---|---|---|
| | | Aeon 1 | Aeon 2 | Olympia | Eden | Chomchaov | Samai | | |
| SLOT 1 | 16th Dec | 10:00am | | | | | 12:30pm | | |
| | 17th Dec | | 12:30pm | | | | | | |
| | 18th Dec | | | | | 12:30pm | | | |
| | 19th Dec | | | | 12:30pm | | | | |
| SLOT 2 | 16th Dec | | 12:30pm | | | 10:00am | | | |
| | 17th Dec | 10:00am | | | | | | | |
| | 18th Dec | | | 7:00pm | | | | | |
| | 19th Dec | | | | 5:30pm | | 12:30pm | | |
| SLOT 3 | 16th Dec | | | | 12:30pm | | | | |
| | 17th Dec | 7:00pm | | | | 10:0am | | | |
| | 18th Dec | | 12:30pm | | | | | | |
| | 19th Dec | | | 2:30pm | | | | | |
| SLOT 4 | 16th Dec | | | 7:00pm | | | | | |
| | 17th Dec | | | | 10:00am | 12:30pm | | | |
| | 18th Dec | 10:00am | | | | | | | |
| | 19th Dec | | 7:00am | | | 10:00am | | | |
| SLOT 5 | 16th Dec | | 7:00pm | | | | | | |
| | 17th Dec | | | 7:00pm | | | | | |
| | 18th Dec | | | | 2:30pm | | 10:00am | | |
| | 19th Dec | 12:30pm | | | | | | | |

គណៈកម្មការរៀបចំមហោស្រព រក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីបញ្ចាំង

The 3rd CSNFF reserve the rights to change the screen program


GENERATION
អត្ថប្រយោជន៍ស៊េរីមេ
សម្រាប់អ្នកមើលភាពយន្តគ្រប់ជំនាន់
នៅគ្រប់សាខា រោងភាពយន្ត មេជើរ ស៊ីនេផ្លិច បាយស្នាត
STUDENT
បញ្ចុះតម្លៃលើសំបុត្រកុន
សន្សំពិន្ទុ ប្តូររង្វាន់ឥតដែនកំណត់
ឃ្មុំស៊ិនច្រើនឥតល្អៃ


HANUMAN
BEVERAGES
ហនុមាន ប៊ែវើរីជីស ឯ.ក
អំពីហនុមាន ប៊ែវើរីជីស
ហនុមាន ប៊ែវើរីជីស ជាក្រុមហ៊ុនផលិតភេសជ្ជៈស្តង់ដារអន្តរជាតិនៅកម្ពុជា ដែលប្តេជ្ញាបង្កើតស្រាបៀរដែលល្អផ្តាច់គេសម្រាប់ប្រជាជនកម្ពុជា ដោយយកចិត្តទុកដាក់បំផុត។
ទស្សនវិស័យ
ដើម្បីក្លាយជាភេសជ្ជៈដែលមានការទទួលស្គាល់នូវគុណភាពល្អ និងពេញនិយមជាងគេ ហើយនាំយកកេរ្តិ៍ឈ្មោះភេសជ្ជៈកម្ពុជា ឈានដល់កម្រិតដ៏អស្ចារ្យមួយ ជាមួយនឹងការច្នៃប្រឌិតខ្ពស់។
បេសកកម្ម
ដើម្បីផលិតភេសជ្ជៈលំដាប់ថ្នាក់ល្អបំផុត ជាមួយនឹងការបន្តស្វែងរករសជាតិថ្មីសម្រាប់ប្រជាជនកម្ពុជា។
គុណតម្លៃ
តួខ្លួនហនុមាន | ឧត្តមភាព លក្ខណៈពិសេស
បេះដូងហនុមាន | ការតាំងចិត្ត ការឆ្ពោះទៅមុខ
ផ្នត់គំនិតហនុមាន | ប្រាជ្ញាដើម្បីជោគជ័យ ឆន្ទៈដើម្បីជ័យជំនះ
តើក្រុមហ៊ុន ហនុមាន ប៊ែវើរីជីស ឯ.ក ត្រូវបានបង្កើតឡើងដើម្បីអ្វី ?
ក្រុមហ៊ុន ហនុមាន ប៊ែវើរីជីស ឯ.ក បង្កើតឡើងដើម្បីរួមចំណែកលើកស្ទួយកម្រិតជីវភាព និងវប្បធម៌រស់នៅរបស់ប្រជាជនកម្ពុជាឱ្យកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។ គ្រប់តំណក់ដែលយើងផលិត គឺប្រកបដោយឆន្ទៈខ្ពស់ ដើម្បីផលិតបាននូវស្រាបៀរល្អឥតខ្ចោះ ជាមួយនឹងការរួមបញ្ចូលនូវរសជាតិថ្មី សម្រាប់ប្រជាជនកម្ពុជា។
សកម្មភាពរបស់យើង
ពាក្យស្លោករបស់ក្រុមហ៊ុន
" ឧត្តមភាពគ្រប់តំណក់ "
Address: Trapaing Veng Village, Chhak Cheurneang Commune, Angsnoul District, Kandal Province, Kingdom of Cambodia
Tel: 023 933 339
Email: info@hanumanbeverages.com
Website: www.hanumanbeverages.com


មកទស្សនារោងភាពយន្ត 22.12.2022
WESTEC MEDIA
AVATAR
វិថីមហាសាគរ
មកទស្សនារោងភាពយន្ត
22.12.2022

## ឧបត្ថម្ភធំដោយ
## Main Sponsors

## ឧបត្ថម្ភដោយ
## Sponsors

## សហការឧបត្ថម្ភដោយ
## Co-Sponsors

ដៃគូសហការផ្សព្វផ្សាយ/ Media Partners

ដៃគូផ្តល់ទីតាំង / Venue Partners

ដៃគូបច្ចេកទេស / Technical Partner

## ដៃគូសហការ / Official Partners